ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន
លេខ:...០០៦.៧.៣.ន.ប.ស្ថ

# សេចក្ដីណែនាំ
## ស្ដីពី
## ការអនុវត្តសាកល្បងប្រព័ន្ធទិន្នន័យសារធាតុបំពុល ដែលសាយភាយ និងបំលាស់ទីចូលទៅក្នុងបរិស្ថាន

ក្រសួងបរិស្ថាន មានកិត្តិយសសូមជម្រាបជូន លោក លោកស្រីជាម្ចាស់ ឬអ្នកទទួលខុសត្រូវទីតាំងផលិតកម្ម (ដូចមានភ្ជាប់ជូនក្នុងបញ្ជីប្រភេទទីតាំងផលិតកម្ម) ទាំងអស់ជ្រាបថា បច្ចុប្បន្ននេះ ក្រសួងបរិស្ថាន ដោយមានកិច្ចសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ បានបញ្ចប់សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការគ្រប់គ្រងប្រព័ន្ធទិន្នន័យសារធាតុបំពុលដែលសាយភាយ និងបំលាស់ទីចូលទៅក្នុងបរិស្ថាន ដែលនឹងត្រូវដាក់ឱ្យអនុវត្តក្រោយការចូលជាធរមាននាពេលខាងមុខនេះ។ នៅក្នុងបទប្បញ្ញត្តិនៃសេចក្ដីព្រាងអនុក្រឹត្យនេះ គឺបានតម្រូវឱ្យទីតាំងផលិតកម្មមួយចំនួន បំពេញកាតព្វកិច្ចផ្ដល់របាយការណ៍ទិន្នន័យសារធាតុបំពុលដែលបានសាយភាយ ឬបំលាស់ទីចេញពីទីតាំងរបស់ខ្លួន។

ដូចនេះ ក្នុងគោលបំណងជួយលើកកម្ពស់ការយល់ដឹង និងសមត្ថភាពជំនាញដល់ទីតាំងផលិតកម្ម ក្នុងការរៀបចំ និងផ្ដល់របាយការណ៍ទិន្នន័យសារធាតុបំពុលដែលត្រូវអនុវត្តជាកាតព្វកិច្ច នាពេលខាងមុខ ក្រសួងបរិស្ថាន នឹងរៀបចំការអនុវត្តសាកល្បងប្រព័ន្ធទិន្នន័យនេះ ដោយស្នើដល់លោក លោកស្រីជាម្ចាស់ ឬអ្នកទទួលខុសត្រូវទីតាំងផលិតកម្មពាក់ព័ន្ធ ចាត់បញ្ជូនឈ្មោះអ្នកតំណាងចំនួន ០២រូប មកក្រសួងបរិស្ថាន ឱ្យបានមុនថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៨ ដើម្បីទទួលបានការបណ្ដុះបណ្ដាលលើការគណនា ឬការប៉ាន់ប្រមាណការសាយភាយ និងការបំលាស់ទីនៃសារធាតុបំពុល ការអនុវត្តសាកល្បងការរៀបចំ និងការផ្ដល់របាយការណ៍ទិន្នន័យសម្រាប់ឆ្នាំសារពើភ័ណ្ឌ២០១៨។

ទទួលបាននូវសេចក្ដីណែនាំនេះ ក្រសួងបរិស្ថានសង្ឃឹម និងជឿជាក់យ៉ាងមុតមាំថា លោក លោកស្រីជាម្ចាស់ ឬអ្នកទទួលខុសត្រូវទីតាំងផលិតកម្មជ្រាបជាព័ត៌មាន និងចូលរួមសហការអនុវត្តតាមខ្លឹមសារនៃសេចក្ដីណែនាំនេះឱ្យមានប្រសិទ្ធភាព។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦១
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៨
ជ.រដ្ឋមន្ត្រី
អនុរដ្ឋលេខាធិការ

ស៊ិន សុធាវ៉ែត

ព័ត៌មានលំអិតសូមទំនាក់ទំនងមក៖
info@prtrcambodiamoe.gov.kh
- លោក អ៊ួន សុគន្ធា ០១២ ៣៨៦ ៦៥៣
- លោកស្រី ជា ស្រីនិត ០៩២ ៣៣៥ ៥៣៤
www.prtrcambodiamoe.gov.kh

# បញ្ជីប្រភេទទីតាំងផលិតកម្មដែលត្រូវជាប់កាតព្វកិច្ចផ្តល់របាយការណ៍

| ល.រ | ប្រភេទទីតាំងផលិតកម្ម | ប្រភេទ | កម្រិតលក្ខខណ្ឌ |
|---|---|---|---|
| ១ | ផលិតទឹកក្រូច ទឹកផ្លែឈើ | ទី១ | កម្មករលើសពី ៥០ នាក់ ឬសមត្ថភាពផលិតលើសពី ១០០០ លីត្រក្នុង ១ ថ្ងៃ |
| ២ | ផលិតស្រាបៀរ | ទី១ | កម្មករលើសពី ៥០ នាក់ ឬសមត្ថភាពផលិតលើសពី ១០០០ លីត្រក្នុង ១ ថ្ងៃ |
| ៣ | ផលិតអាល់កុល ឬមេតាណុល | ទី១ | កម្មករលើសពី ៥០ នាក់ ឬសមត្ថភាពផលិតលើសពី ១០០០ លីត្រក្នុង ១ ថ្ងៃ |
| ៤ | ផលិតម្សៅដំឡូង ឬម្សៅមី | ទី១ | កម្មករលើសពី ៥០ នាក់ ឬសមត្ថភាពផលិតលើសពី ៥ តោនក្នុង ១ ថ្ងៃ |
| ៥ | ផលិតអំពៅ ឬស្ករស | ទី១ | កម្មករលើសពី ៥០ នាក់ ឬសមត្ថភាពផលិតលើសពី ៥ តោនក្នុង ១ ថ្ងៃ |
| ៦ | បង្កជ័រកៅស៊ូក្រែប | ទី១ | កម្មករលើសពី ២០ នាក់ ឬសមត្ថភាពផលិតលើសពី ៣ តោនក្នុង ១ ថ្ងៃ |
| ៧ | បោកគក់ក្រណាត់ ឬសំលៀកបំពាក់ | ទី១ | កម្មករលើសពី ២០ នាក់ |
| ៨ | ជ្រលក់ពណ៌អំបោះ ឬក្រណាត់ | ទី១ | កម្មករលើសពី ២០ នាក់ |
| ៩ | ផលិតស៊ីម៉ង់ត៍ | ទី១ | គ្រប់ទំហំ |
| ១០ | ផលិតថាមពលអគ្គិសនីដើរដោយការដុតឥន្ទនៈផូស៊ីល ឬសំណល់ | ទី១ | គ្រប់ទំហំ |
| ១១ | សម្លាប់ស្បែកសត្វ | ទី១ | គ្រប់ទំហំ |
| ១២ | ផលិត ឬកែច្នៃផលិតផលជាសារធាតុគីមីៈ ថ្នាំពណ៌ ល័ក្សពណ៌ សារធាតុបោកជម្រះ | ទី២ | គ្រប់ទំហំ |
| ១៣ | ផលិតជីគីមី និងថ្នាំពុលកសិកម្ម | ទី២ | គ្រប់ទំហំ |
| ១៤ | ទាញយក កិន ឬញែករ៉ែលោហៈធាតុ | ទី២ | គ្រប់ទំហំ |
| ១៥ | ទាញយកប្រេងកាតឆៅ និងឧស្ម័នធម្មជាតិ | ទី២ | គ្រប់ទំហំ |
| ១៦ | ចម្រាញ់រ៉ែលោហៈធាតុ | ទី២ | គ្រប់ទំហំ |
| ១៧ | ចម្រាញ់ប្រេងកាត | ទី២ | គ្រប់ទំហំ |

| | | | |
|---|---|---|---|
| ១៨ | ក្រុមហ៊ុនស្រោបលោហៈ រួមមាន៖ ការស្រោបលោហៈលើបន្ទះស័ង្កសី ការបាញ់ថ្នាំពណ៌លើម៉ាស៊ីន គ្រឿងចក្រ ឬយានយន្ត | ទី២ | គ្រប់ទំហំ |
| ១៩ | រោងចក្រកែច្នៃសំណល់អគ្គិសនី សំណល់អេឡិចត្រូនិក និងសំណល់ប្រេងឥន្ធនៈ | ទី២ | គ្រប់ទំហំ |
| ២០ | ទីលានចាក់សំណល់រឹងឧស្សាហកម្ម | ទី២ | គ្រប់ទំហំ |
| ២១ | រោងចក្រឡដុតសំរាម សំណល់រឹងទីប្រជុំជន ឬសំណល់គ្រោះថ្នាក់ | ទី២ | គ្រប់ទំហំ |
| ២២ | រោងចក្រប្រព្រឹត្តកម្មទឹកល្អទីប្រជុំជន រាជធានី ខេត្ត | ទី២ | គ្រប់ទំហំ |